**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃពុធ ១១ រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥*

*រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២២*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ
# ស្តីពីគោលនយោបាយ និង ទិសដៅនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា

បច្ចេកវិទ្យាឌីជីថល ជាផ្នែកមួយដ៏សំខាន់នៃជីវិតរស់នៅប្រចាំថ្ងៃ និង ផ្តល់នូវកាលានុវត្តភាពសម្រាប់ការបង្កើតនូវធុរកិច្ចថ្មីៗដែលមានសក្តានុពល និង នវានុវត្តន៍។ រាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការទាញយកឧត្តមប្រយោជន៍ជាអតិបរមាពីបច្ចេកវិទ្យាឌីជីថលក្នុងការកសាងសេដ្ឋកិច្ចឌីជីថលដែលនឹងក្លាយជាសសរស្តម្ភដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់ប្រទេសកម្ពុជា។ ក្នុងបរិការណ៍នៃជំងឺកូវីដ-១៩, បច្ចេកវិទ្យាឌីជីថលបានចូលរួមចំណែកកាន់តែខ្លាំងក្នុងការរក្សាស្ថិរភាព និង សកម្មភាពសេដ្ឋកិច្ច, ការជំរុញពិពិធកម្មសេដ្ឋកិច្ច និង ការបង្កើតឱកាសការងារក៏ដូចជាអាជីវកម្មថ្មីៗដែលមានសក្តានុពល។ ក្នុងន័យនេះ, ឌីជីថលូបនីយកម្មបានក្លាយជានិន្នាការ និង ជាកម្លាំងចលករដ៏មានឥទ្ធិពល ក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា។

កាលពីខែ ឧសភា ឆ្នាំ ២០២១, រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ **"ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥"** ដោយចាត់ទុកសេដ្ឋកិច្ចឌីជីថល ជាចន្ទល់កំណើនសេដ្ឋកិច្ចថ្មីផង និង ជាប្រព័ន្ធអេកូឡូស៊ីរួមចំណែកបង្កើនផលិតភាពសេដ្ឋកិច្ចនៅក្នុងវិស័យផ្សេងទៀត។ បច្ចេកវិទ្យាហិរញ្ញវត្ថុដែលជាទូទៅត្រូវបានគេហៅថា FinTech គឺជាមូលដ្ឋានដ៏ចាំបាច់មួយផងដែរ ក្នុងនិម្មាបនកម្មសេដ្ឋកិច្ចឌីជីថល។ យ៉ាងណាមិញ, វិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាបាននិងកំពុងប្រឈមមុខជាមួយបញ្ហាមួយចំនួន រួមមាន៖ កង្វះខាត និង ភាពមិនច្បាស់លាស់ក្នុងក្របខណ្ឌបទប្បញ្ញត្តិ, កង្វះខាតការគាំទ្រដល់ការអនុវត្តឌីជីថល, កង្វះខាតធនធានមនុស្ស និង កង្វះខាតនូវនវានុវត្តន៍បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យដទៃទៀត ក្រៅពីវិស័យធនាគារ។

ដើម្បីកសាងវិធានគោលនយោបាយរួមក្នុងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា, **គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល នៃក្រុមប្រឹក្សាជាតិសេដ្ឋកិច្ច និង សង្គមឌីជីថល** បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី **"គោលនយោបាយ និង ទិសដៅនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា"** រយៈពេលមួយថ្ងៃកន្លះ នាថ្ងៃទី ២៦ និង ២៧ ខែ មេសា ឆ្នាំ ២០២២ វេលាម៉ោង ៨:៣០ នាទី ព្រឹក នៅ សណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ (Hyatt Regency Phnom Penh)។ សិក្ខាសាលានេះត្រូវបានប្រារព្ធឡើង ក្រោមអធិបតីភាពដ៏

ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល ហើយក៏មានការអញ្ជើញចូលរួមពី ថ្នាក់ដឹកនាំក្រសួង, តំណាងក្រសួង-ស្ថាប័ន, ស្ថានទូត, ដៃគូអភិវឌ្ឍន៍, គ្រឹះស្ថានហិរញ្ញវត្ថុធនាគារ និងមិនមែនធនាគារ, សមាគម, ក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ, ធុរជន និង នវានុវត្តជន។

សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី **"គោលនយោបាយ និង ទិសដៅនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា"** ត្រូវបានរៀបចំឡើងក្នុងគោលបំណងសំខាន់ៗចំនួន ៣ រួមមានៈ (១) ប្រមូលធាតុចូលពីដៃគូពាក់ព័ន្ធសម្រាប់ការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា, (២) លើកកម្ពស់ការយល់ដឹងអំពីការវិវត្តវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន និង បញ្ហាប្រឈមក្នុងប្រទេសកម្ពុជា, និង (៣) ចែករំលែកគំនិត និង ទស្សនវិស័យរបស់អ្នកជំនាញ ដែលមានគោលដៅក្នុងការជំរុញការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា។ សិក្ខាសាលានេះបានប្រព្រឹត្តទៅយ៉ាងរលូន និង ទទួលបានលទ្ធផលដូចការរំពឹងទុក ដោយមានអន្តរសកម្ម និង ការពិភាក្សាគ្នាយ៉ាងផុសផុលរវាងវាគ្មិន និង អ្នកចូលរួម ប្រកបដោយស្មារតីចែក-រំលែក និងយកចិត្តទុកដាក់ខ្ពស់។ តាមរយៈសិក្ខាសាលានេះ **គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល** ទទួលបាននូវធាតុចូលល្អៗជាច្រើនពីអ្នកចូលរួមដែលជាអ្នកជំនាញ និង មានបទពិសោធន៍ក្នុងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ ក៏ដូចជាបានយល់ដឹងកាន់តែស៊ីជម្រៅពីឧត្តមានុវត្តន៍, ក្របខណ្ឌបទប្បញ្ញត្តិ, បញ្ហាប្រឈម និង ការវិវត្តចុងក្រោយនៃវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ក៏ដូចជានៅបណ្តាប្រទេសដែលជាសមាជិកអាស៊ាន រួមមានប្រទេសសិង្ហបុរី, ថៃ, ឥណ្ឌូនេស៊ី និង ហ្វីលីពីន ផងដែរ។

សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនេះ គឺជាជំហានចាប់ផ្តើមដ៏ល្អនៅក្នុងដំណើរការនៃការតាក់តែងសេចក្តីព្រាងគោលនយោបាយដែលមានលក្ខណៈប្រទាក់ក្រឡា, មុតស្រួច, គ្រប់ជ្រុងជ្រោយ, និង ងាយបត់បែនប្រកបដោយប្រសិទ្ធភាព និង បរិយាបន្ន។ យ៉ាងណាមិញ, ការបន្តប្រមូលធាតុចូលល្អៗឱ្យបានកាន់តែច្រើន និងជាក់លាក់ពីតួអង្គពាក់ព័ន្ធក្នុងវិស័យសំខាន់ៗនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងដំណើរតាក់តែងសេចក្តីព្រាងគោល-នយោបាយនេះពិតជាមានភាពចាំបាច់។ ក្នុងន័យនេះ, **គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល** នឹងបន្តរៀបចំសិក្ខាសាលាជាបន្តបន្ទាប់ទៅតាមវិស័យនីមួយៗ ដូចជាវិស័យធានារ៉ាប់រង, វិស័យធនាគារ និង វិស័យហិរញ្ញវត្ថុវិមជ្ឈការ (Decentralized Finance)។

**គណៈកម្មាធិការសេដ្ឋកិច្ច និង ធុរកិច្ចឌីជីថល** មានជំនឿចិត្តយ៉ាងមុតមាំថា **គោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា** នឹងចូលរួមចំណែកក្នុងការកំណត់នូវទិសដៅ គោលការណ៍ និង វិធានការគោលនយោបាយ ក្នុងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា សម្រាប់ទាំងវិស័យហិរញ្ញវត្ថុធនាគារ, វិស័យហិរញ្ញវត្ថុមិនមែនធនាគារ និង វិស័យហិរញ្ញវត្ថុវិមជ្ឈការ ប្រកបដោយយុទ្ធសាស្ត្រ និង ភាពគ្រប់ជ្រុងជ្រោយ។ ការណ៍នេះនឹងអាចជួយកសាងមូលដ្ឋានក្នុងការរៀបចំផែនការសកម្មភាពអាទិភាព និង ជាក់លាក់ សំដៅអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលនៅកម្ពុជា។